ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ៖ ០១ សណន

# សេចក្តីណែនាំ

## ស្តីពី

## ការកសាងឯកសារចុះបញ្ជីដីធ្លី

មុននឹងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្រសួងបានចេញឯកសារបណ្តុះបណ្តាលជំនាន់ទី១ នាខែ មករា ឆ្នាំ២០០៣ និងជំនាន់ទី២ នាខែមីនា ឆ្នាំ ២០០៤ និងបានដំណើរការបណ្តុះបណ្តាលមន្ត្រីជំនាញទាំងអស់ អំពីនីតិវិធីនៃការបំពេញទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី តែក្នុងការអនុវត្តន៍ជាក់ស្តែង ក្រសួងបានពិនិត្យឃើញថាការកសាងឯកសារចុះបញ្ជីដីធ្លីនៅតាមខេត្ត-ក្រុងអនុវត្តគំរោងមួយចំនួនមានការធ្វេសប្រហែស ខ្វះការទទួលខុសត្រូវ ទាំងនីតិវិធី និងទិដ្ឋភាពគតិយុត្ត ពិសេសទាក់ទងនឹងការកំណត់អត្តសញ្ញាណម្ចាស់អចលនវត្ថុ ។

ដើម្បីចៀសវាងកំហុសឆ្គង និងបាតុភាពខាងលើ ក្រសួងធ្វើការណែនាំ ដូចខាងក្រោម ៖

១-មន្ត្រីវិនិច្ឆ័យ ត្រូវផ្អែកលើច្បាប់ និងបទដ្ឋានគតិយុត្តដែលមានជាធរមានក្នុង ការកំណត់អត្តសញ្ញាណម្ចាស់អចលនវត្ថុជាអាទិ៍ ៖ ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត ទីកន្លែង កំណើត សញ្ជាតិ សាវតា និងស្ថានភាពស៊ីវិល នៅពេលបំពេញទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

២-មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ និងទទួលខុសត្រូវ រាល់ទិន្នន័យនៅក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

៣- មន្ត្រីបញ្ចូលទិន្នន័យ (GIS) ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ ។ ទិន្នន័យដែលបញ្ចូលក្នុងកុំព្យូទ័រ ត្រូវតែធានាត្រឹមត្រូវ ។ មន្ត្រីទទួលបន្ទុកមិនត្រូវកែប្រែ ឬបន្ថែមឱ្យខុសពីទិន្នន័យនៃទំរង់បែបបទ តាមទំនើងចិត្តឡើយ ពុំនោះនឹងត្រូវប្រឈមនឹងច្បាប់ និងបទបញ្ជាជាធរមាន។



អាស័យដ្ឋាន ៖ លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659 - 215 660 , Fax : (855) 023 215 277, e-mail : im. c . lim. @ Camnet. Com. kh

៤-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រុង ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកត្រួតពិនិត្យគុណភាព ។ មន្ត្រីទទួលបន្ទុកនេះ ត្រូវផ្សេងពីមន្ត្រីបញ្ចូលទិន្នន័យ ។

( ភ្ជាប់ជាមួយឯកសារឧបសម្ព័ន្ធណែនាំស្តីពីការកសាងឯកសារចុះបញ្ជីដីធ្លី )

ទទួលបានសេចក្តីណែនាំនេះ គ្រប់មន្ទីរអនុវត្តគំរោងទាំងអស់ត្រូវចាត់ចែងអនុវត្ត ខ្ជាប់ខ្ជួនសារខាងលើអោយមានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦

ជ.នាយករដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ឆាន់_សាផាន

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលាខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ

ឯកសារឧបសម្ពន្ធ ឯកសារណែនាំស្តីពីការកសាងឯកសារចុះបញ្ជីដីធ្លី លេខ.១១..ចុះថ្ងៃ.២១..កក្កដា.២០០៦

**សញ្ជាតិ :**

១-ច្បាប់ភូមិបាល មាត្រា៨

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា ។ អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៅកម្ពុជាគឺពលរដ្ឋខ្មែរទាំងអស់ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ ឬសមាគមកម្ពុជា សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មកម្ពុជានិងគ្រប់អង្គភាពកម្ពុជាដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល ។

ជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិដើម្បីឱ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជានឹងត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៥១ នៃច្បាប់នេះ ។ ទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋមិនចេញសំណងឱ្យឡើយ ។

២-ក្នុងឯកសារបណ្តុះបណ្តាលក្រុមចុះបញ្ជីដីធ្លីជំនាន់ទី១ ខែមករា២០០៣ត្រង់ចំណុចសញ្ជាតិក្នុងទំព័រទី១២៥បានបញ្ជាក់ថា:

○ <u>សំរាប់រូបវន្តបុគ្គល</u> : ប្រសិនបើមានអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន ដែលបង្ហាញពីសញ្ជាតិរបស់បុគ្គលនោះយ៉ាងច្បាស់លាស់ ។ ប្រសិនបើមិនមានឯកសារណាផ្តល់អោយទេមន្ត្រីវិនិច្ឆ័យត្រូវបំពេញទំរង់បែបបទស្របទៅតាមអ្វីដែលម្ចាស់ដីឬ ភោគី និងសាក្សី ផ្សេង ទៀតនិយាយប្រាប់ ។

ត្រូវប្រុងប្រយ័ត្នមិនត្រូវច្រឡំរវាងពាក្យ " ជនជាតិខ្មែរ " និង " សញ្ជាតិខ្មែរ " នោះទេ។ សញ្ជាតិខ្មែរ គឺមិនមែនទាក់ទងទៅនិងភាពជាជនជាតិខ្មែរទេ។ ឧទាហរណ៍ជនជាតិដើមភាគតិចមួយចំនួនធំជនជាតិ ចាម ចិន នៅប្រទេសកម្ពុជា ពួកគេមានសញ្ជាតិខ្មែរ ពីកំណើត ប៉ុន្តែមិនមែនជាជនជាតិខ្មែរទេ ។ មនុស្សម្នាក់អាចទទួលបានសញ្ជាតិខ្មែរប្រសិនបើឪពុកឬម្តាយរបស់ខ្លួនជាជនជាតិខ្មែរ ឬ ប្រសិនបើមនុស្សនេះបានកើតនៅប្រទេសកម្ពុជាស្របតាមលក្ខខណ្ឌជាក់លាក់ ( មាត្រា៤ នៃច្បាប់ស្តីពី សញ្ជាតិចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៦ ) ឬ បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ជាមួយសញ្ជាតិខ្មែរស្របតាមលក្ខណ្ឌជាក់លាក់ ( មាត្រា ៥ និង ៦ នៃច្បាប់នេះ ) ឬ ដោយការធ្វើ សញ្ជាតូបនីយកម្ម ( មាត្រា៧ ដល់១៧ នៃច្បាប់នេះ ) ។

៣-ក្នុងឯកសារបណ្តុះបណ្តាលក្រុមចុះបញ្ជីដីធ្លី ជំនាន់ទី២ ខែមីនា ២០០៤ត្រង់ចំណុចសញ្ជាតិ ទំព័រទី១២ បានបញ្ជាក់ថា:

| | | |
|---|---|---|
| សញ្ជាតិ | ខ្មែរ | ខ្មែរ |

គឺសំអាងលើឯកសារ ដូចជាអត្តសញ្ញាណប័ណ្ណ ឬសំបុត្រអត្រានុកូលដ្ឋាន ឬសៀវភៅគ្រួសារ ឬលិខិតឆ្លងដែន។ តាមច្បាប់មានតែបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាកម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា ។

ភារកិច្ចទទួលខុសត្រូវ : ក្នុងឯកសារបណ្តុះបណ្តាលទាក់ទងការងារ GIS ក៏បានបញ្ជាក់នូវភារកិច្ចរបស់មន្ត្រី GIS ដូចខាង ក្រោម :

ត្រួតពិនិត្យ គុណភាព ( ត្រួតពិនិត្យអត្ថន័យ និងត្រួតពិនិត្យគុណភាព )

ទិន្នន័យនៃការចុះបញ្ជីដីធ្លី គឺជាទិន្នន័យមានសារៈសំខាន់ ពិតមានរបស់វានិយាយអំពីម្ចាស់កម្មសិទ្ធិនិងសិទ្ធិជាកម្មសិទ្ធិ ។